ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ០២៤/០៩ កប/ ស.ជ.ណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី ១២៣ ទិវាពលកម្មអន្តរជាតិ

## ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ រាជធានី-ខេត្ត សមាគមនិយោជក និង និយោជក សហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព និងសហជីព ព្រមទាំងកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ថា យោង អនុក្រឹតលេខ ១៤៣ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីប្រក្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៩ និង ប្រកាសលេខ ២១៤ កប/ប្រក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួលប្រចាំឆ្នាំ ២០០៩ សូមអស់លោក លោកស្រី យកចិត្តទុកដាក់នូវប្រកាសរួមមួយចំនួនដូចខាងក្រោមៈ

១-គ្រប់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន ត្រូវចាត់ចែងអោយមានការឈប់សំរាក នៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ ។ ក្នុងករណីចាំបាច់បំផុត ដែលសហគ្រាស គ្រឹះស្ថានមិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនក្នុងឱកាសថ្ងៃ ឈប់បុណ្យ នេះបានទេ ម្ចាស់និងនាយកសហគ្រាស គ្រឹះស្ថានត្រូវសម្របសម្រួលជាមួយកម្មករនិយោជិត ឱ្យមានការស្ម័គចិត្ត ។ កម្មករនិយោជិត ដែលធ្វើការថ្ងៃឈប់បុណ្យនេះ មានសិទ្ធិទទួលនូវការឈប់សំរាកសងនៅថ្ងៃណាមួយក្នុងសប្តាហ៍ ឬទទួលប្រាក់បំណាច់ ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា ។

២-សហព័ន្ធសហជីព និង សហជីពតាមសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួល និង សហការជាមួយ និយោជក ដើម្បីចាត់តាំងការជួបជុំនៅតាមសហគ្រាស គ្រឹះស្ថាន ចាត់តាំងកម្មវិធីទទួលអំណរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា តាមរូបភាពផ្សេងៗ និងតាមលទ្ធភាពរៀងៗខ្លួន ។

៣-សហព័ន្ធសហជីព និង សហជីពតាមសហគ្រាស គ្រឹះស្ថានទាំងឡាយ ពុំគប្បីយកឱកាសទិវាអន្តរជាតិ ថ្ងៃ០១ ខែ ឧសភា ដែលជាថ្ងៃបុណ្យការងារ និងជាថ្ងៃឈប់សំរាកការងាររបស់កម្មករនិយោជិត ដើម្បីបង្កនូវបាតុភាពទាំងឡាយណាដែល នាំឱ្យមានអំពើហឹង្សា ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់សង្គម ឬ រំខានដល់គោលបំណងខាងលើឡើយ ។

-ក្នុងនៃនេះ សហព័ន្ធសហជីព គប្បីចាត់តាំងពិធីជួបជុំសំណេះសំណាលអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ នៅតាមទីស្នាក់សហព័ន្ធរៀងៗខ្លួន ដើម្បីត្រងត្រាប់ស្តាប់ ឬផ្សព្វផ្សាយ សារលិខិតសម្តេច អគ្គមហាសេបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា សារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈព្រមទាំងធ្វើពិធីកំសាន្ត

សប្បាយរីករាយតាមរូបភាព និងលទ្ធភាពជាក់ស្តែង ។

-សូមអស់លោក លោកស្រី សហការឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ចថែរក្សាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កម្មវិធីសប្បាយរីករាយរបស់កម្មករនិយោជិត តាមសហគ្រាសគ្រឹះស្ថានដែលបោះទីតាំងក្នុងមូលដ្ឋាន ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា សមាគមនិយោជក និង និយោជក ព្រមទាំងសហព័ន្ធ សហជីព និងកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរជាពុំខាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០៩

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

<u>**ចម្លងជូន**</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យ សម្តេចមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ទីស្តីការគណរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ

« ដើម្បីជូនជ្រាប »

-អគ្គនាយកដ្ឋានការងារ

-អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី

« ដើម្បីផ្សព្វផ្សាយ និង អនុវត្ត »

-សមាគមនិយោជក « ដើម្បីជ្រាប និង អនុវត្ត »

-សហព័ន្ធសហជីព « ដើម្បីជ្រាប និង អនុវត្ត»

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ « ដើម្បីជួយផ្សព្វផ្សាយ »

-រាជកិច្ច

- ឯកសារ-កាលប្បវត្ត